# ការជ្រើសរើសអ្នកស្ម័គ្រចិត្តបកប្រែ ឯកសារនិងផ្ទាល់មាត់ ពេលមានគ្រោះមហន្តរាយ

យើងកំពុងស្វែងរកអ្នកស្ម័គ្រចិត្តដែលអាចសហការក្នុងការបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់នៅពេលមានគ្រោះមហន្តរាយធំៗ កើតឡើង!!




1 អ្វីទៅជាការស្ម័គ្រចិត្តបកប្រែឯកសារ និងផ្ទាល់មាត់ពេលមានគ្រោះមហន្តរាយ

វាគឺជាការស្ម័គ្រចិត្តបកប្រែឯកសារ និង បកប្រែផ្ទាល់មាត់ នៅមណ្ឌលជំនួយពហុភាសាអំពីគ្រោះមហន្តរាយប្រចាំខេត្តកាណាហ្គាវ៉ា នៅពេលដែលមានគ្រោះមហន្តរាយធំៗ កើតមានឡើង។ ក្នុងចំណោមអ្នកដែលបានចុះឈ្មោះជាមុន យើងខ្ញុំនឹងស្នើអ្នកដែលអាចសហការដែលបកប្រែឯកសារ និង បកប្រែផ្ទាល់មាត់។

2 អំពីសកម្មភាពស្ម័គ្រចិត្ត

①. ការឆ្លើយតបជាភាសាបរទេស ទៅនឹងការពិគ្រោះយោបល់ និង សំណូមពរ ពីជនបរទេស (បុគ្គលិកយើងខ្ញុំនឹងជួយអ្នកអំពីខ្លឹមសារនៃការឆ្លើយតប)

②. ការបកប្រែជាភាសាបរទេសពីព័ត៌មានដែលបានផ្សាយចេញជាភាសាជប៉ុន ពីស្នាក់ការកណ្តាលទប់ស្កាត់គ្រោះមហន្តរាយនៅខេត្ត កាណាហ្គាវ៉ា។

3 កន្លែងធ្វើសកម្មភាព

នៅក្នុងមណ្ឌលជំនួយពហុភាសាកាណាហ្គាវ៉ា (Kanagawa Kenmin Center ជាន់ទី 13)

2-24-2 Tsuruya-cho, Kanagawa-ku, Yokohama-shi, Kanagawa

※ការងារបកប្រែអាចត្រូវបានស្នើសុំអោយធ្វើនៅផ្ទះ

4 ភាសាជ្រើសរើស

គ្រប់ភាសាទាំងអស់

ជាពិសេសយើងកំពុងពង្រឹងការជ្រើសរើសអ្នកដែលអាចនិយាយ ភាសាថៃ ភាសាវៀតណាម ភាសាឡាវ និងភាសាខ្មែរជាដើម។ ប្រសិនបើអ្នកស្គាល់នរណាម្នាក់ដែលមានចំណាប់អារម្មណ៍ សូមណែនាំអំពីប្រព័ន្ធស្ម័គ្រចិត្តនេះ។

※សូមទាញយកខិត្តប័ណ្ណអំពីការជ្រើសរើស ពីទីនេះ




5 គុណវឌ្ឍិ

មិនចាំបាច់មានគុណវឌ្ឍិទាក់ទងនឹងភាសាទេ។ យើងខ្ញុំក៏មិនគិតអំពីប្រវត្តិដូចជា ការរៀននៅសាលា ឬការរៀនដោយខ្លួនឯង ឬដោយការប្រើប្រាស់នៅកន្លែងធ្វើការជាដើមទេ។

6 លក្ខខណ្ឌនៃការចុះឈ្មោះ

អ្នកដែលអាចមកជុំគ្នានៅ មណ្ឌលជំនួយពហុភាសាអំពីគ្រោះមហន្តរាយ ប្រចាំខេត្តកាណាហ្គាវ៉ា នៅពេលមានគ្រោះមហន្តរាយធំៗ កើតឡើង

7 របៀបចុះឈ្មោះ

សូមបំពេញព័ត៌មានចាំបាច់ដែលមាននៅក្នុង "សំណុំបែបបទស្ម័គ្រចិត្តជួយបកប្រែឯកសារ និងផ្ទាល់មាត់ពេលមានគ្រោះមហន្តរាយ" រួចផ្ញើទៅកាន់អាសយដ្ឋានខាងក្រោមនេះ តាមរយៈប្រៃសណីយ៍ ទូរសារ ឬ តាមអ៊ីម៉ែល។ យើងខ្ញុំនឹងចុះឈ្មោះពេលបានទទួលការដាក់ពាក្យរបស់អ្នក។

※សូមទាញយក "សំណុំបែបបទស្ម័គ្រចិត្តជួយបកប្រែឯកសារ និងផ្ទាល់មាត់ពេលមានគ្រោះមហន្តរាយ" ពីទីនេះ

＜អាសយដ្ឋានទំនាក់ទំនង＞

| | |
|---|---|
| អាសយដ្ឋាន | លេខកូដប្រៃសណីយ៍ 231-8588 Kanagawa-ken, Yokohama-shi, Naka-ku, Nihon-Odori 1 |
| ឈ្មោះ | ផ្នែកផែនការនៃនាយកដ្ឋានអន្តរជាតិ ការិយាល័យជីវភាពរស់នៅនៃពលរដ្ឋ នៃខេត្ត កាណាហ្គាវ៉ា |
| ទូរស័ព្ទ | 045-210-3748（ហៅផ្ទាល់） |
| ទូរសារ | 045-212-2753 |
| អ៊ីម៉េល | 0804p_kokusai@pref.kanagawa.jp |

8 អ្វីទៅជាមណ្ឌលជំនួយពហុភាសាអំពីគ្រោះមហន្តរាយប្រចាំខេត្តកាណាហ្គាវ៉ា

គឺជាមណ្ឌលមួយដែលទទួលការប្រឹក្សា ឬ បកប្រែ និងការផ្សព្វផ្សាយព័ត៌មានជាច្រើនភាសាពេលមានគ្រោះមហន្តរាយកើតមានឡើង តាមរយៈការសហការណ៍រវាងខេត្តកាណាហ្គាវ៉ានិងមូលនិធិការផ្លាស់ប្តូរវប្បធម៌អន្តរជាតិ(មូលនិធិការប្រាក់សាជីវកម្មសាធារណៈ)។

※កិច្ចព្រមព្រាងរវាង ខេត្តកាណាហ្គាវ៉ា និងមូលនិធិការផ្លាស់ប្តូរវប្បធម៌អន្តរជាតិ(មូលនិធិការប្រាក់សាជីវកម្មសាធារណៈ) មាននៅទីនេះ (ជាភាសាជប៉ុន)